**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)**
**លេខាធិការដ្ឋាន**

លេខ: ០០៩ សសរ/គ.ជ.អ.ប

ថ្ងៃសុក្រ ៩រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៩

# សេចក្ដីសម្រេច
## ស្ដីពីការបង្កើតគណៈកម្មាធិការផ្ដល់មូលនិធិ
## នៃមូលនិធិផ្អែកលើលទ្ធផលនៃការអនុវត្តសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្ដីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ២៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ២៣៤ អនក្រ.បក ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១១ ស្ដីពីការកែសម្រួលមាត្រា៤ មាត្រា៧ មាត្រា៨ មាត្រា១២ មាត្រា១៥ និងមាត្រា១៧ និងបន្ថែមមាត្រា១២ស្ទួន នៃអនុក្រឹត្យលេខ២៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- សៀវភៅណែនាំស្ដីពីមូលនិធិផ្អែកលើលទ្ធផលនៃការអនុវត្តសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩

## សម្រេច

**ប្រការ១ ÷** ត្រូវបានបង្កើតគណៈកម្មាធិការផ្ដល់មូលនិធិ នៃមូលនិធិផ្អែកលើលទ្ធផលនៃការអនុវត្តសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។

មហាវិថីព្រះនរោត្តម: លេខាធិការដ្ឋាន គ.ជ.អ.ប ក្រសួងមហាផ្ទៃ ។ ទូរស័ព្ទ: (៨៥៥-២៣) ៧២០ ០៦១ / ៧២០ ០៣៨ E-mail: info@ncdd.gov.kh Website: www.ncdd.gov.kh
Norodom Blvd., National Committee for Sub-National Democratic Development Secretariat (NCDDS). Ministry of Interior. Tel: (855-23) 720 061 / 720 038

**ប្រការ២ ÷** ត្រូវបានតែងតាំងប្រធាន និងសមាជិកក្នុងគណៈកម្មាធិការផ្តល់មូលនិធិ នៃមូលនិធិផ្អែកលើលទ្ធផលនៃការអនុវត្តសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិដូចមានរាយនាមខាងក្រោម៖

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម **នី គីមសាន** | អនុប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប | ជាប្រធាន |
| ២. | តំណាងសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាមូលដ្ឋាន | | ជាសមាជិក |
| ៣. | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | | ជាសមាជិក |
| ៤. | តំណាងក្រសួងកិច្ចការនារី | | ជាសមាជិក |
| ៥. | តំណាងក្រសួងបរិស្ថាន | | ជាសមាជិក |
| ៦. | តំណាងក្រសួងមហាផ្ទៃ | | ជាសមាជិក |

**ប្រការ៣ ÷** គណៈកម្មាធិការផ្តល់មូលនិធិមានតួនាទីដូចខាងក្រោម៖

- ពិនិត្យ និងអនុម័តលើគោលបំណង និងការចំណាយដែលអាចទូទាត់បានរបស់មូលនិធិ
- ពិនិត្យ និងអនុម័តលើលក្ខខណ្ឌអប្បបរិមាក្នុងការទទួលបាននូវមូលនិធិ
- ពិនិត្យ និងអនុម័តលើការវាស់វែងការអនុវត្តរបស់ភ្នាក់ងារអនុវត្តមូលនិធិ
- ពិនិត្យ និងអនុម័តលើលក្ខណៈវិនិច្ឆ័យសម្រាប់ជ្រើសរើសក្រុង ស្រុកគោលដៅ
- ពិនិត្យ និងអនុម័តលើការបែងចែកមូលនិធិផ្អែកលើលទ្ធផលនៃការអនុវត្តដល់ភ្នាក់ងារអនុវត្តមូលនិធិ
- ធានាឱ្យមានភាពយុត្តិធម៌ និងតម្លាភាពចំពោះការផ្តល់មូលនិធិ
- និងតាមដាន ត្រួតពិនិត្យ និងឆ្លើយតបទៅនឹងបណ្តឹងតវ៉ាចំពោះការប្រើប្រាស់មូលនិធិ។

**ប្រការ៤ ÷** គណៈកម្មាធិការផ្តល់មូលនិធិ ត្រូវអនុវត្តស្របទៅតាមសៀវភៅណែនាំស្តីពីមូលនិធិផ្អែកលើលទ្ធផលនៃការអនុវត្តសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩។

**ប្រការ៥ ÷** អង្គភាពគ្រប់គ្រង និងគាំទ្រកម្មវិធីនៃលេខាធិការដ្ឋាន គ.ជ.អ.ប សម្របសម្រួលរៀបចំកិច្ចប្រជុំ រៀបចំគោលបំណង រៀបចំបញ្ជីការចំណាយដែលអាចទូទាត់បាន រៀបចំលក្ខណៈវិនិច្ឆ័យជ្រើសរើសក្រុង ស្រុក រៀបចំបញ្ជីក្រុងស្រុកគោលដៅ រៀបចំការបញ្ជីបែងចែកមូលនិធិ រៀបចំរបាយការណ៍នៃការវាយតម្លៃការអនុវត្តមូលនិធិ និងផ្សព្វផ្សាយព័ត៌មានស្តីពីមូលនិធិផ្អែកលើលទ្ធផលនៃការអនុវត្ត ស្របទៅតាមសៀវភៅណែនាំស្តីពីមូលនិធិផ្អែកលើលទ្ធផលនៃការអនុវត្តសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ដាក់ជូនគណៈកម្មាធិការមូលនិធិពិនិត្យ និងសម្រេច។

**ប្រការ៦ ÷** ប្រធាន និងសមាជិកនៃគណៈកម្មាធិការមូលនិធិដូចមានចែងក្នុងប្រការ២ និងអង្គភាពចំណុះនៃលេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវអនុវត្តនូវសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**

**ង៉ាន់ ចំរើន**